រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០០៤/១៨ របក អ.ជ.ប.គ.ញ

ថ្ងៃចន្ទ ១២កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៧ និងទិសដៅការងារ ឆ្នាំ២០១៨

(ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧)

ឆ្នាំ២០១៧នេះ ជាឆ្នាំដែលមានលក្ខណៈពិសេសជាងបណ្តាឆ្នាំមុនៗ អាស្រ័យដោយរាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខ បានដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដែលបានប្រមូលផ្តុំសមាសភាពពីគ្រប់មជ្ឈដ្ឋានរបស់សង្គមក្នុងការ អនុវត្តយ៉ាងសកម្មភ្លៀវក្លាបន្ថែមទៀតពីលើការអនុវត្តបទបញ្ជាលេខ០១បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផែនការជាតិ៣ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ តាមរយៈ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់, បទបញ្ជាលេខ ០១ បប និងផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានកត់សម្គាល់ទៅលើសភាពការណ៍គ្រឿងញៀនអន្តរជាតិ ក៏ដូចជាសភាពការណ៍គ្រឿងញៀនជាតិ ព្រមទាំងអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

ឆ្នាំ២០១៧នេះ ក៏ដូចជាបណ្តាឆ្នាំមុនៗ ទាំងនៅក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ នៅតែបន្តទទួលរងឥទ្ធិពលនៃការផលិត ការចរាចរគ្រឿងញៀនពីតំបន់មួយចំនួនដូចជា តំបន់អាមេរិកខាងត្បូង តំបន់អាហ្វ្រិក តំបន់អឌ្ឍចន្ទមាស និងត្រីកោណមាស ។ ជាមួយនឹងស្ថានភាពនេះ ពិភពលោកក៏នៅតែប្រឈមជាមួយនឹងកំណើននៃអ្នកប្រើប្រាស់គ្រឿងញៀន រួមទាំងសកម្មភាពប្រើបំពានសារជាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

ដោយឡែក តំបន់ត្រីកោណមាសនៅតែបន្តមានសកម្មភាពដាំដុះអាភៀន និងផលិតហេរ៉ូអ៊ីន មេតំហ្វេតាមីនក្រាមម្សៅ(ICE) មេតំហ្វេតាមីនគ្រាប់(WY) គួរឱ្យកត់សម្គាល់នៅឡើយ ។ ជាក់ស្តែង ប្រភេទគ្រឿងញៀន និងរុក្ខជាតិញៀនទាំងនោះ ត្រូវបានគេដាំដុះនិងផលិតក្នុងមួយឆ្នាំៗប្រមាណជា ១.០០០ តោន និងជាង ១.០០០ លានគ្រាប់ និងសារជាតុគីមីផ្សំប្រមាណជាង ១.០០០ តោន[1] ។

ដោយសារសភាពការណ៍គ្រឿងញៀនដូចខាងលើ ធ្វើឱ្យកម្ពុជានៅតែបន្តទទួលរងផលប៉ះពាល់ពីការចរាចរគ្រឿងញៀនឆ្លងកាត់ពីបណ្តាប្រទេសនានា ទាំងនៅក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ដែលយើងបានធ្វើការកត់សម្គាល់ដូចខាងក្រោម ៖

[1] តាមការវាយតម្លៃរបស់អង្គការ UNODC



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

- ការចរាចរគ្រឿងញៀនឆ្លងកាត់ពីបណ្តាប្រទេសជិតខាង ភាគច្រើនគឺចូលតាមច្រកផ្លូវគោកនៃបណ្តាខេត្តនៅភាគខាងជើង និងឦសានប្រទេស
- ការចរាចរគ្រឿងញៀនឆ្លងកាត់ពីតំបន់អាមេរិកខាងត្បូង តំបន់អាហ្វ្រិក តំបន់អឌ្ឍចន្ទមាស ភាគច្រើនគឺធ្វើឡើងតាមផ្លូវអាកាស និងបញ្ញើប្រៃសណីយ៍

ជាមួយនឹងការចរាចរគ្រឿងញៀនឆ្លងកាត់ យើងបានកត់សម្គាល់ក្នុងរយៈពេលចុងក្រោយនេះ ការលបលួចដាំដុះដំណាំកញ្ឆា បានកើតមាននៅតាមបណ្តាខេត្តមួយចំនួន ។

## II. អំពីការដឹកនាំ

ក្នុងគោលបំណងជំរុញការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់តាំងពីថ្នាក់ដឹកនាំកំពូលថ្នាក់ជាតិ ក៏ដូចជាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងថ្នាក់ក្រោមជាតិ បានរៀបចំកម្លាំង និងចាត់តាំងអនុវត្តដូចខាងក្រោម ៖

### ១. ការដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

**ក្នុងនាមរាជរដ្ឋាភិបាល សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បាន ៖

- ទទួលដំណើរទស្សនកិច្ចផ្លូវការរបស់ នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម អញ្ជើញមកកម្ពុជា (ថ្ងៃទី២៤-១៦ ខែមេសា ឆ្នាំ២០១៧) និងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃ (ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៧) ក្នុងនោះមានរបៀបវារៈមួយ ដែលនាយករដ្ឋមន្ត្រី នៃប្រទេសទាំងពីរ បានគាំទ្រ និងជួយលើការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅខេត្តព្រះសីហនុ
- ប្រគល់ភារកិច្ចជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដឹកនាំការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដោយប្រមូលផ្តុំសមាសភាពពីគ្រប់មជ្ឈដ្ឋានរបស់សង្គម អនុវត្តនូវវិធានការសរុប ប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប ពង្រឹងយន្តការដែលមានស្រាប់ និងរៀបចំយន្តការចាំបាច់បន្ថែមនិងកសាងផែនការសកម្មភាពមួយចំនួនទៀត ដើម្បីអនុវត្តផែនការយុទ្ធនាការនេះប្រកបដោយប្រសិទ្ធភាពមានការទទួលខុសត្រូវ និងទទួលបាននូវការគាំទ្រ និងវាយតម្លៃខ្ពស់ពីសាធារណមតិជាតិ និងអន្តរជាតិ ។

### ២. ការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន** ក៏បានណែនាំនូវគោលការណ៍សំខាន់ៗក្នុងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់, បទបញ្ជាលេខ០១ បប ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់រាជរដ្ឋាភិបាល ក៏ដូចជាផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទិសដៅការងារដែលបានដាក់ចេញកាលពីឆ្នាំ២០១៦ មានដូចតទៅ ៖

**២.១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវបន្តវិធានការផ្សព្វផ្សាយអប់រំតាមរយៈ ការរៀបចំវេទិកាតុមូល ការអប់រំសិស្ស និស្សិត កម្មកររោងចក្រ-សហគ្រាស កម្មករសំណង់នានា ការផ្សព្វផ្សាយតាមបណ្តាញព័ត៌មាន មានដូចជា តាមប្រព័ន្ធទូរស័ព្ទ ស្ថានីយវិទ្យុ-ទូរទស្សន៍រដ្ឋនិងឯកជន ការបិទតាំងខ្លឹមសារអប់រំតាមគោលដៅទេសចរណ៍ ការរៀបចំវេទិកាជួបវិស័យឯកជន ។

**២.២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និង ការចាកចេញពីគ្រឿងញៀន ៖** បន្តពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្ន ដើម្បីទទួលជនរងគ្រោះដែលអង្គភាពអនុវត្តន៍ច្បាប់ ស្ថាប័នតុលាការ បញ្ជូនមកទទួលសេវាព្យាបាល និងត្រូវពង្រឹងនិងពង្រីកសេវាព្យាបាល ដោយផ្អែកលើសហគមន៍នៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកបន្ថែមទៀត ។ ជាមួយនេះ ត្រូវរៀបចំជួសជុលមណ្ឌលសុខុមាលភាពសង្គម របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានស្រាប់នៅក្នុងភូមិឆ្លក សង្កាត់គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ សម្រាប់ទទួលអ្នកញៀនគ្រឿងញៀន ។ ទន្ទឹមនេះ ត្រូវរៀបចំដាក់ឱ្យដំណើរការនូវមជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀន នៅកងពលតូចអន្តរាគមន៍លេខ១១ នៅភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត និងបន្តការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

**២.៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តបើកវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ តាមរយៈការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន និងសារធាតុគីមីផ្សំ តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ**(CBT)**, តាមប្រព័ន្ធអេឡិចត្រូនិក( **eLearning)** និងការបណ្តុះបណ្តាលជំនាញផ្សេងៗទៀតដល់មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ក៏ដូចជាមន្ត្រីបម្រើការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន **(BLO)** ។

**២.៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** ត្រូវបញ្ចប់ការកែសម្រួលសមាសភាពក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

**២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** បន្តអនុវត្តនូវរាល់កិច្ចការដែលបានព្រមព្រៀងគ្នាកន្លងមកជាមួយភាគីថៃ ឡាវ និងវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ព្រមទាំងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់ប្រទេសកម្ពុជា ថៃ និងឡាវ ជាពិសេសការកសាងភូមិ ស គ្មានគ្រឿងញៀននៅតាមព្រំដែន ដែលភាគីកម្ពុជា ឡាវ និងថៃ បានឯកភាពគ្នាកន្លងមក និងការពង្រឹងពង្រីកការិយាល័យ**(BLO)** តាមបណ្តោយព្រំដែន កម្ពុជា-ឡាវ, កម្ពុជា-ថៃ ។

**២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖** បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយអង្គការ( **UNODC**) បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ និងគម្រោងសហប្រតិបត្តិការជាមួយការិយាល័យអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ក៏ដូចជាគម្រោងសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project) ពិសេសការពង្រឹងប្រសិទ្ធភាពការិយាល័យ**(BLO)** ។

**២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវបន្តការកែសម្រួលមាត្រាមួយចំនួននៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើសគ្រឿងញៀន និងបន្តស្នើសុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ក្រៅពីការណែនាំនូវគោលការណ៍សំខាន់ៗដូចខាងលើ ក្នុងនាមថ្នាក់ដឹកនាំ អ.ជ.ប.គ.ញ. ៖

- **ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំប្រតិភូទៅទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម(ថ្ងៃទី១៨-២១ ខែមេសា ឆ្នាំ២០១៧ ដែលប្រតិភូទាំងពីរបានឯកភាពថានឹងបន្តការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់, បំពាក់សម្ភារ, និងផ្តល់

ឱសថសម្រាប់ព្យាបាលអ្នកញៀនគ្រឿងញៀន

- ជួបជាមួយគណៈប្រតិភូចិន ដោយផ្តោតជាសំខាន់ទៅលើការពង្រឹងទំនាក់ទំនង និងសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ចិន ក្នុងការទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន ក៏ដូចជាឧក្រិដ្ឋកម្មឆ្លងដែន ។ បន្ថែមលើនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានស្នើឱ្យភាគីចិនជួយកម្ពុជាបន្ថែមទៀតលើវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀន ពិសេសក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅទូទាំង ប្រទេស

- ជួបពិភាក្សាការងារជាមួយ ឯកឧត្តម Adol Lale Demoz នាយករងប្រតិបត្តិអង្គការ(UNODC) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី ដោយបានសន្យាបន្តជួយកម្ពុជាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងអនុតំបន់ ដើម្បីពង្រឹងប្រសិទ្ធភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា

- ជួបពិភាក្សាការងារជាមួយ អគ្គលេខាធិការនៃគណៈកម្មការជាតិត្រួតពិនិត្យគ្រឿងញៀនចិន ដោយផ្តោតសំខាន់លើការបន្តជួយគាំទ្រទាំងថវិកា សម្ភារបច្ចេកទេស និងការបណ្តុះបណ្តាលធនធានមនុស្ស ដល់កម្ពុជាសម្រាប់ឆ្នាំ ២០១៧-២០១៨ ។

- **ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** បានដឹកនាំប្រតិភូកម្ពុជាទៅចូលរួមនៅក្នុងកិច្ចប្រជុំស្តីពីផែនការប្រតិបត្តិក្នុងតំបន់ត្រីកោណមាសជាមួយបណ្តាប្រទេសផ្តល់ជំនួយ

- បានអញ្ជើញជាអធិបតីក្នុងពិធីបើកកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់នៃប្រទេសហត្ថលេខីអនុស្សរណៈ នៃការយោគយល់គ្នា (MOU) ១៩៩៣ ស្តីពីការត្រួតពីនិត្យគ្រឿងញៀនក្នុងមហាអនុតំបន់ទន្លេមេគង្គ (ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៧) នៅសណ្ឋាគារ Rafal Le Royal

- បានជួបពិភាក្សាជាមួយឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ថៃ (ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧) ដោយផ្តោតការយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី កម្ពុជា-ថៃ ពាក់ព័ន្ធនឹងការពង្រឹងការត្រួតពិនិត្យគ្រឿងញៀននៅតាមបណ្តោយព្រំដែន, ការបង្កើតការិយាល័យ BLO បន្ថែម និងការជួយសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាដោយផ្អែកលើសហគមន៍ នៅខេត្តព្រះសីហនុ

- បានដឹកនាំជាសហប្រធានកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសហត្ថលេខីអនុស្សរណៈ នៃការយោគយល់គ្នា (MOU)១៩៩៣ ស្តីពីការត្រួតពីនិត្យគ្រឿងញៀន ក្នុងមហាអនុតំបន់ទន្លេមេគង្គ ជាមួយអង្គការ (UNODC) កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ ពាក់ព័ន្ធនឹងការអនុវត្តផែនការសកម្មភាពអន់តំបន់ លើកទី៩ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងអនុម័តលើផែនការសកម្មភាពអនុតំបន់ លើកទី១០ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

# III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

### ១.១ ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ÷

គ្រប់ក្រសួង-ស្ថាប័ន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានចូលរួមអនុវត្តយ៉ាងផុលផុសតាមស្មារតីនៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដោយបានផ្តល់កិច្ចសម្ភាសន៍ជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ-ទូរទស្សន៍រដ្ឋ-ឯកជន), រៀបចំវេទិកាគុមូល ពាក់ព័ន្ធនឹងការងារបង្ការ ទប់ស្កាត់ការចរាចរ ជួញដូរ រក្សាទុក ប្រើប្រាស់ និងការព្យាបាលអ្នកញៀនគ្រឿងញៀនជាប់ជាប្រចាំ ។

ដោយឡែក តាមរយៈគេហទំព័រ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានអ្នកចូលអានសរុបប្រមាណ **៦២១.៩៤០** ដង ។

### ១.២ កម្មវិធីអប់រំផ្សព្វផ្សាយតាមសហគមន៍ ÷

១.២.១. ក្រសួង-ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ. និងក្រសួង-ស្ថាប័នពាក់ព័ន្ធ បាន ៖

- អប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់មន្ត្រីរាជការ ប្រជាពលរដ្ឋទូទាំងប្រទេសបានចំនួន **២.៨២៨.៦៨០** នាក់
- បណ្តុះបណ្តាលព្រះសង្ឃបង្គោល និងជនបង្គោលជាលោកគ្រូ-អ្នកគ្រូ សិស្ស-និស្សិត បុគ្គលិកក្រុមហ៊ុន រោងចក្រ-សហគ្រាស បានចំនួន **១០.៦៨៥** នាក់

១.២.២. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនទាំង ២៥ រាជធានី-ខេត្ត បានធ្វើការបញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមសហគមន៍ បានប្រមាណ **៦.៨០៨.៦៨៦** នាក់

សរុបអ្នកបានទទួលសារអប់រំពីបញ្ហាគ្រឿងញៀនមាន **៩.៦៤០.០២១** នាក់ ប្រៀបធៀបឆ្នាំ២០១៦ មាន **១៣.៧៧៤.៧៣៩** នាក់ ថយចុះ **៤.១៣៤.៧១៨** នាក់ ស្មើនឹង ៣០,០១ % មូលហេតុគឺដោយសារឆ្នាំនេះការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនថយចុះ (ប៉ុន្តែគុណភាពនៃការអប់រំ យើងធ្វើបានចំគោលដៅក្រុមងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ និងបណ្តុះបណ្តាលជនបង្គោលបានច្រើន) ។

- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដំឡើងបាណូអប់រំផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការទប់ស្កាត់ បង្ក្រាបបទល្មើស និងផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ចំនួន ១៤ ផ្ទាំង នៅតាមខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ឡាវ និងប្រើប្រាស់ខិត្តប័ណ្ណផ្សព្វផ្សាយគ្រប់ប្រភេទសរុប **១១០.៧០១** សន្លឹក ។
- ក្រសួងទេសចរណ៍ ដំឡើងបាណូអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ចំនួន ២០ ផ្ទាំង ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់ ÷

ដើម្បីកាត់បន្ថយគ្រោះថ្នាក់នានា ដែលមានការពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួងសុខាភិបាលជាសេនាធិការ បានផ្តល់ការគាំទ្រដល់សេវាព្យាបាលជំនួសដោយឱសថមេតាដូននៅក្នុងមន្ទីរពេទ្យថ្នាក់ជាតិ និងអនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលចំនួន ២ អនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំង។

ជាមួយនេះ អ.ជ.ប.គ.ញ. បានសម្របសម្រួលនិងចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន មន្ត្រីក្រសួង-ស្ថាប័នសមាជិក និងអង្គការដៃគូពាក់ព័ន្ធឱ្យទៅចូលរួមក្នុងកិច្ចប្រជុំនានា ទាំងក្នុង និងក្រៅប្រទេសសរុប ១៦ លើក មន្ត្រីចូលរួមសរុប **៤៨៣** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **៣២** នាក់) ក្នុងនោះ ៖

- នៅក្នុងប្រទេស ១៤ លើក មន្ត្រីចូលរួមសរុប **៤៨១** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **៣០** នាក់)
- នៅក្រៅប្រទេស ២ លើក មន្ត្រីចូលរួមសរុប **២** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **២** នាក់) ។

កម្មវិធីទាំងនោះរួមមាន ៖

- កិច្ចប្រជុំគណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍និងគ្រឿងញៀននៅកន្លែងធ្វើការ
- កិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលអនុវត្តគម្រោងកម្មវិធីសិក្សាស្រាវជ្រាវពីការបង្ការមេរោគអេដស៍ និងគ្រឿងញៀន នៅប្រទេសកម្ពុជា
- កិច្ចប្រជុំដៃគូក្រុមប្រឹក្សាយោបល់របស់មជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាមេរោគអេដស៍នៃតំបន់អាស៊ីអាគ្នេយ៍

- កិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលការអង្កេតស្រាវជ្រាវចំណេះដឹងពីជំងឺអេដស៍ គ្រឿងញៀន ការប្រព្រឹត្ត ផ្លូវភេទនិងរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមនារីបម្រើតាមសេវាកម្សាន្តសប្បាយ នៅប្រទេសកម្ពុជា ឆ្នាំ២០១៦
- កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការរៀបចំនិយាមប្រតិបត្តិដើម្បីដាក់បញ្ចូល ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងវិនិយោគឃុំ-សង្កាត់ ។

**២.២. វគ្គបំប៉នសមត្ថភាពលើការងារព្យាបាល និងស្តារនីតិសម្បទា ៖**

អ.ជ.ប.គ.ញ. បានសម្របសម្រួល និងចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន មន្ត្រីក្រសួង-ស្ថាប័នសមាជិក និងអង្គការដៃគូពាក់ព័ន្ធឱ្យទៅចូលរួមក្នុងកិច្ចប្រជុំនានា ទាំងនៅក្នុងនិងក្រៅប្រទេស ១០ លើក មន្ត្រីចូលរួមសរុប **៣១៧** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **២៤** នាក់) ។ ក្នុងនោះ ៖

- នៅក្នុងប្រទេស ៥ លើក មន្ត្រីចូលរួមសរុប **២៥៣** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **១៤** នាក់)
- នៅក្រៅប្រទេស ៥ លើក មន្ត្រីចូលរួមសរុប **៦៤** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **១០** នាក់) ។

កម្មវិធីទាំងនោះ រួមមាន ៖

- កិច្ចប្រជុំគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- វគ្គបណ្តុះបណ្តាលគ្រូបង្គោលការងារព្យាបាល ថែទាំអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- វគ្គបណ្តុះបណ្តាលពីឯកសារគោលសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀន
- ទស្សនកិច្ចសិក្សាស្តីពីការព្យាបាលនិងស្តារនីតិសម្បទា ដល់មន្ត្រីពាក់ព័ន្ធរបស់ខេត្តជាប់ព្រំដែន ។

ក្រៅពីនេះយើងបាន ៖

- ដាក់ឱ្យដំណើរការមណ្ឌលសុខុមាលភាពសង្គម របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅក្នុងភូមិធ្លក សង្កាត់គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ, មជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀន នៅកងពលតូចអន្តរាគមន៍ លេខ ១១ នៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត និងមជ្ឈមណ្ឌលក្របេះឱកាសថ្មី
- បន្តដំណើរការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

**២.៣. ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ៖**

២.៣.១. បានដំឡើងស្លាកសញ្ញាសម្គាល់សេវាព្យាបាលជំងឺផ្លូវចិត្តនិងភាពញៀនគ្រឿងញៀនបាន ១៦១ កន្លែង និងកំពុងធ្វើបន្តទៀត ។

២.៣.២. បានពង្រីកសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ តាមប្រព័ន្ធសុខាភិបាល បាន **៤១៩** កន្លែង ក្នុងនោះ មន្ទីរពេទ្យថ្នាក់ជាតិ ២ កន្លែង, មន្ទីរពេទ្យខេត្ត ២៤ កន្លែង, មន្ទីរពេទ្យបង្អែក ៧២ កន្លែង, មណ្ឌលសុខភាព ៣២១ កន្លែង ។

២.៣.៣. ចំនួនអ្នកប្រើប្រាស់គ្រឿងញៀនដែលបានធ្វើបច្ចុប្បន្នភាពចុងឆ្នាំ២០១៧ មាន **១៨.១០៤** នាក់ លើ ២០.៦២១ នាក់ ធៀបឆ្នាំ២០១៦ (ថយចុះ ២៥១៧ នាក់ ស្មើ ១២,២០%) ។ ក្នុងនោះ ៖

- អ្នកប្រើគ្រឿងញៀន **១៤.៣៥៣** នាក់ ៧៩.២៨% ដែលកំពុងរស់នៅតាមភូមិ-ឃុំ-សង្កាត់ រួមមាន :
  - អ្នកប្រើគ្រឿងញៀន ដែលបានសមាហរណកម្មចេញពីមណ្ឌល ៨.៩៤៤ នាក់ ស្មើ ៤៩,៤០%
  - អ្នកប្រើគ្រឿងញៀន ដែលកំពុងទទួលសេវាព្យាបាលដោយផ្អែកលើសហគមន៍ **៣.១០១** នាក់ ស្មើ ១៧,១៣%

- អ្នកប្រើគ្រឿងញៀន នៅមិនទាន់ទទួលបានការព្យាបាលមាន ២.៣០៨ នាក់ ស្មើ ១២,៧៤%

- អ្នកប្រើគ្រឿងញៀន ដែលកំពុងបន្សាបព្យាបាលនៅតាមមណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋ និងឯកជន **៣.៧៥១** នាក់ ស្មើ ២០,៧២%

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ ៖

អ.ជ.ប.គ.ញ. បានសម្របសម្រួល រៀបចំ និងចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្ដុះបណ្ដាល ទស្សនកិច្ចសិក្សាដកបទពិសោធន៍ ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេសសរុប **៥៦** លើក មានមន្ត្រីចូលរួម **២១៦៣** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១២៦ នាក់) រួមមាន ៖

- នៅក្នុងប្រទេស ៣៨ លើក មន្ត្រីចូលរួមសរុប **១.៨២៥** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ៨០ នាក់)
- នៅក្រៅប្រទេស ១៨ លើក មន្ត្រីចូលរួមសរុប **៣៣៨** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ៤៦ នាក់) ។

ក្នុង **២១៦៣** នាក់នេះ មន្ទីរប្រឆាំងគ្រឿងញៀនបណ្ដុះបណ្ដាលបាន **៧៩១** នាក់ ។ កម្មវិធីទាំងនោះមាន ៖

- ការពង្រឹងសមត្ថភាពការិយាល័យ BLO ជុំវិញអនុតំបន់ទន្លេមេគង្គ (របស់អគ្គរដ្ឋអាជ្ញាកូរ៉េ)
- វគ្គបណ្ដុះបណ្ដាលមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ និងប្រព័ន្ធអេឡិចត្រូនិច
- វគ្គបណ្ដុះបណ្ដាលស្ដីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ និងការប្រើប្រាស់តេស្តបឋមសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀនតាមព្រំដែន
- វគ្គបណ្ដុះបណ្ដាលមន្ត្រីអនុវត្តន៍ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន (របស់ប្រទេសចិន)
- វគ្គបណ្ដុះបណ្ដាលស្ដីពីការត្រួតពិនិត្យសារធាតុគីមីដែលមានគ្រោះថ្នាក់ និងសិក្ខាសាលាស្ដីពីសុវត្ថិភាពជាសកលពាក់ព័ន្ធការប្រើប្រាស់សារធាតុគីមីដែលមានគ្រោះថ្នាក់
- សិក្ខាសាលាស្ដីពីមន្ទីរពិសោធន៍លួចលាក់
- វគ្គសិក្សាច្បាប់ស្ដីពីការត្រួតពិនិត្យសារធាតុញៀនថ្មីដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ
- វគ្គបណ្ដុះបណ្ដាលស្ដីពីយុទ្ធសាស្ត្រនៃការត្រួតពិនិត្យទំនិញនាំចេញក្រៅប្រទេស
- វគ្គបណ្ដុះបណ្ដាលស្ដីពីការណែនាំកម្មវិធីត្រួតពិនិត្យកុងតឺន័រ ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន ៖

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៨.១៧៣** ករណី (ឆ្នាំ២០១៦មាន ៤.២៤៦ ករណី) កើនឡើង ៣.៩២៧ ករណី ស្មើនឹង ៩២,៤៨ %

- **ជនសង្ស័យ** ឃាត់ខ្លួន **១៧.៨០០** នាក់ / ស្រី **១.៥៨៦** នាក់ (ឆ្នាំ២០១៦មាន ៩.៩៣៣ នាក់ ) កើនឡើង ៧.៨៦៧ នាក់ ស្មើនឹង ៧៩,២០ % ។ ក្នុងនោះ ៖

- បទល្មើសកែច្នៃផលិត **៣** ករណី / ជនសង្ស័យ **៧** នាក់ (ស្រី ២ នាក់)
- បទល្មើសជួញដូរ **៥.៣៤៤** ករណី / ជនសង្ស័យ **៩.៥៩៥** នាក់ (ស្រី ១.១១៨ នាក់)
- បទល្មើសដាំដុះ **១៦** ករណី / ជនសង្ស័យ **១** នាក់ ប្រុស
- បទល្មើសប្រើប្រាស់ **២.៨១០** ករណី / ជនសង្ស័យ **៨.១៩៧** នាក់ (ស្រី ៤៦៤ នាក់)

ក្នុងចំណោមជនសង្ស័យខាងលើ មានសញ្ជាតិ : ខ្មែរ ១៧.៥២៧ នាក់, វៀតណាម ២១០ នាក់, ឡាវ ១០ នាក់, ចិន ៦ នាក់, បារាំង ៥ នាក់, ជប៉ុន ១ នាក់, អាមេរិក ៣ នាក់, ថៃ ៧ នាក់, ហ្វីលីពីន ១ នាក់, នីហ្សេរីយ៉ា ៧ នាក់,

ម៉ាឡេស៊ី ២ នាក់, ឥណ្ឌូនេស៊ី ៣ នាក់, ញូហ្សេឡែន ១ នាក់, វ៉េណេហ្ស៊ុយអេឡា ១ នាក់, កូឡុំប៊ី ៣ នាក់, ចិនតៃវ៉ាន់ ២ នាក់, រុស្សី ១ នាក់, អាហ្វ្រិកខាងត្បូង ១ នាក់, ស៊ុយអែត ១ នាក់, អង់គ្លេស ១ នាក់, ស្លូវ៉ានៀល ១ នាក់, អូស្ត្រាលី ៣ នាក់, ឥណ្ឌា ១ នាក់, ប៊ែលហ្សិក ១ នាក់, សឹង្ហបុរី ១ នាក់, ។

ក្នុងចំនួនបទល្មើស និង ជនសង្ស័យខាងលើមាន **៧** ករណី ដែលមន្ទីរប្រឆាំងគ្រឿងញៀនបានសហការជាមួយមន្ត្រីនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, អគ្គនាយកដ្ឋានគយនិងរដ្ឋាករ, ប្រៃសណីយ៍និងទូរគមនាគមន៍ និងកម្លាំង ចម្រុះប៉ុស្តិ៍ច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម និងចាប់យកគ្រឿងញៀនប្រភេទ មេតំហ្វេតាមីន, អ៊ិចស្តាស៊ី កេតាមីន ប្រមាណជាង ២៥ គ.ក្រ ។

**គ្រឿងញៀនចាប់យកសរុប ២៩៦ គ.ក្រ ៨២១ ក្រាម ក្នុងនោះរួមមាន ៖**

- **សរុបគ្រឿងញៀនសំយោគ ១៨០ គ.ក្រ ២៣០ ក្រាម**
  - មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៨០ គ.ក្រ ១២៥ ក្រាម ៤២០ មិល្លីក្រាម
  - មេតំហ្វេតាមីនគ្រាប់ (WY) ៣៣ គ.ក្រ ៤៤០ ក្រាម ០៧០ មិល្លីក្រាម
  - អ៊ិចស្តាស៊ី ២៥ គ.ក្រ ០៦៣ ក្រាម ៣៥០ មិល្លីក្រាម
  - ហេរ៉ូអ៊ីន ២២ គ.ក្រ ៥៣៤ ក្រាម ៤៦០ មិល្លីក្រាម
  - កូកាអ៊ីន ១២ គ.ក្រ ៨១៣ ក្រាម ៣៨០ មិល្លីក្រាម
  - កេតាមីន ៦ គ.ក្រ ២៥៣ ក្រាម ៣២០ មិល្លីក្រាម
- **រុក្ខជាតិញៀន**
  - កញ្ឆាក្រៀម ១១៦ គ.ក្រ ២៩១ ក្រាម
  - កញ្ឆាស្រស់ ៣០៣.០៥២ ដើម

- **ទ្រព្យសម្បត្តិសំខាន់ៗ** ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត រួមមាន ៖ រថយន្ត ៨៨ គ្រឿង, ម៉ូតូ ២.២៤៦ គ្រឿង, ប្រាក់កម្ពុជា ៩៧.៦៣៦.៧០០ រៀល, ប្រាក់ថៃ ៧១.៧៣៧ បាត, ប្រាក់វៀតណាម ៣.៣០៨.៤០០ ដុង, ប្រាក់អាមេរិក ២៤.៣៨៣ ដុល្លារ

- **អចលនទ្រព្យ** ដែលបានបង្កករួមមាន : ដីធ្លី ផ្ទះ ចំនួន ១៣ កន្លែង ។

- **ជនសង្ស័យ** ចាប់តាមដីកា មាន ២៩១ ដីកា ឃាត់ខ្លួនជនសង្ស័យ ២៨៦ នាក់ (ស្រី ២៦ នាក់) ។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល ៖

- បានរុះរើបន្ទប់ជួលពាក់ព័ន្ធបទល្មើសគ្រឿងញៀន ១០១ បន្ទប់, កន្លែងផ្ញើម៉ូតូ ៧ កន្លែង
- បានធ្វើតេស្តរកសារធាតុញៀនលើជនជាប់ឃុំ នៅតាមមន្ទីរអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្តសរុបចំនួន ១៦.៦៣០ នាក់ រកឃើញវិជ្ជមានសារធាតុញៀន ៩៤ នាក់
- បានធ្វើតេស្តរកសារធាតុញៀនលើក្មេងទំនើង និងជនមានតម្រុយប្រើប្រាស់គ្រឿងញៀន ចំនួន ៥៣២ លើក ស្មើនឹង ៦.៨០៦ នាក់ រកឃើញអ្នកផ្ទុកសារធាតុញៀន ២២៤ នាក់

### ៣.៤. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ៖

មន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាង ដែលសង្ស័យជាគ្រឿងញៀនបាន **៤.១១០** សំណាក = **៣.៦២៤** ករណី ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន ៣.៧០៨** សំណាក (៩០,២១%) = **៣.៤៩៥** ករណី គឺ ៖

- មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៣.៤២៥ សំណាក (៨៣,៣៣ %)
- មេតំហ្វេតាមីនគ្រាប់ (WY) ១៥៧ សំណាក (៣,៨១ %) - កូកាអ៊ីន ៧ សំណាក (០,១៧%)
- កេតាមីន ៣៥ សំណាក (០,៨៥ %) - MDMA ៤២ សំណាក (១,០២ %)
- ហេរ៉ូអ៊ីន ២៣ សំណាក (០,៥៥ %) - ឌីយ៉ាហ្សេប៉ាម ៧សំណាក (០,១៧ %)
- កញ្ឆា ១៣ សំណាក (០,៣១ %)

- ***សំណាកអវិជ្ជមានសារធាតុញៀន* ៤០២** សំណាក = **១២៩** ករណី (៩,៧៨%)

ក្រៅពីការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន មន្ទីរពិសោធន៍របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានផ្តល់ដល់ស្ថាប័នអនុវត្តន៍ច្បាប់ រួមមាន អគ្គស្នងការដ្ឋាននគបាលជាតិ អគ្គនាយកដ្ឋានពន្ធនាគារ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត មន្ទីរប្រឆាំងគ្រឿងញៀន ស្នងការដ្ឋាននគបាល-បញ្ញាការដ្ឋាន កងរាជអាវុធហត្ថរាជធានី-ខេត្ត កងទ័ពជើងទឹក កងពលតូចលេខ៧០ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានូវ ៖

- ស្រោមវេចខ្ចប់សំណាកសង្ស័យជាគ្រឿងញៀន សរុបចំនួន ៣.១៦៥ ស្រោមខ្ចប់
- តេស្តរកសារធាតុញៀនក្នុងទឹកនោម ៤១.១៦៥ តេស្ត - ម៉ាគ្វីតេស្ត ១.៦១០ តេស្ត និង២៤ ដប
- កេតាមីនតេស្ត ៥៥ តេស្ត - កូកាអ៊ីន ១៥០ តេស្ត
- អេហ្វេឌ្រីន ៣០ តេស្ត - ស៊ីម៉ុនតេស្ត ១៥ តេស្ត / ដប ១១ ដប

## ៣.៥. ចំណាត់រឿងក្តីពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន

- សំណុំរឿងបទល្មើសគ្រឿងញៀនសរុប **៩២៧** រឿង ចែកចេញជា ៖ បទល្មើសជួញដូរ ៥១៥ រឿង, បទល្មើសចែកចាយ ៤ រឿង, បទល្មើសជួញដូរនិងប្រើប្រាស់ ១១៥ រឿង, បទល្មើសចែកចាយនិងប្រើប្រាស់ ២៤ រឿង, បទល្មើសរក្សាទុកប្រើប្រាស់សារធាតុញៀនខុសច្បាប់ ១៤៥ រឿង, បទល្មើសជួញដូរនិងរក្សាទុក ៥៩ រឿង, បទល្មើសជួញដូរ និងចែកចាយសារធាតុញៀន ៤ រឿង, បទល្មើសសមគំនិតនិងផ្តល់ទីតាំងជួញដូរសារធាតុញៀន ១ រឿង, បទល្មើសប្រើប្រាស់ ៦០ រឿង ។

- ជនល្មើសសរុប ១.២៧០ នាក់ ចែកចេញជា ៖
  - នីតិជន ប្រុស : ១.០៨១ នាក់, នីតិជន ស្រី ៨០ នាក់
  - អនីតិជន : ប្រុស ១០២ នាក់, អនីតិជន ស្រី ៧ នាក់ ។

- បានដុតបំផ្លាញវត្ថុតាងគ្រឿងញៀន តាមអំណាចសាលក្រម សាលដីកាស្ថាពរ របស់សាលាដំបូងរាជធានីភ្នំពេញ និងខេត្តចំនួន ០២ នៅក្នុងទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមមាន ៖

- សាលាដំបូងរាជធានីភ្នំពេញដុតបំផ្លាញគ្រឿងញៀន មេតំហ្វេតាមីនក្រាមម្សៅ មេតំហ្វេតាមីនគ្រាប់ អ៊ិចស្តាស៊ី ហេរ៉ូអ៊ីន កេតាមីន សរុបចំនួន ១២៦ គ.ក្រ ០៣១ ក្រាម

- សាលាដំបូងខេត្តកំពង់ចាម និងខេត្តប៉ៃលិន ដុតបំផ្លាញគ្រឿងញៀន មេតំហ្វេតាមីនក្រាមម្សៅ ១២០,៣ ក្រាម, ២ កញ្ចប់ធំ, ៤ កញ្ចប់តូច និងមេតំហ្វេតាមីនគ្រាប់ ១៦០ គ្រាប់

- បានដុតបំផ្លាញវត្ថុតាងគ្រឿងញៀន តាមអំណាចសាលក្រម សាលដីកាស្ថាពរ របស់សាលាដំបូងខេត្តចំនួន ៤ គឺ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ ប៉ៃលិន ព្រះវិហារ កំពង់ធំ សៀមរាប ឧត្តរមានជ័យ ស្ទឹងត្រែង ក្រចេះ រតនគិរី មណ្ឌលគិរី ស្វាយរៀង ព្រៃវែង ត្បូងឃ្មុំ និងខេត្តកំពង់ចាម នៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមមាន ៖ មេតំហ្វេតាមីន WY ២៥៨.៤៨០ គ្រាប់, មេតំហ្វេតាមីន WY គ្រាប់ដែលរលាយជាប់គ្នា ៣.៦៨៥,៥ ក្រាម, ICE ៥៨ គ.ក្រ ៤០៦ ក្រ ៤៣៨ មិល្លីក្រាម, ICE កញ្ចប់ធំ ២៦១

កញ្ចប់, ICE កញ្ចប់តូច ១៩២៧ កញ្ចប់, ថ្នាំគ្រាប់ប្រភេទ LV (អ៊ិចស្តាស៊ី) ៥១.៥៦៤ គ្រាប់, ម៉េ្យាម៉ដ្តព័ណស ៣.៥៦៩,៥ ក្រាម, ហេរ៉ូអ៊ីន ២.១០២ ក្រាម, កញ្ឆាក្រៀម ១៦៦ គ.ក្រ និង ១២ កញ្ចប់តូច, ថ្នាំគ្រាប់ព័ណខៀវ ៩៧៧,៨ គ្រាប់, កេតាមីន ៥ កញ្ចប់ធំ, កូកាអ៊ីន ២ កញ្ចប់ធំ, កញ្ឆាគ្រាប់ ២ ថង់ និង ១ ដបទឹកសុទ្ធ

• ក្រសួងយុត្តិធ៌ម បានចុះពង្រឹងប្រធាន-អនុប្រធាន ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ចៅក្រម ក្រឡាបញ្ជី នៅតាមសាលាដំបូងរាជធានី-ខេត្ត ចំនួន ១.០១៤ នាក់ ពាក់ព័ន្ធនឹងការពង្រឹងលើចំណាត់ការរឿងក្តីបទល្មើសគ្រឿងញៀន ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

• សារជាតុគីមីពាក់ព័ន្ធនឹងតារាង**ទី៤** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានអាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់មុខសញ្ញាស្តង់ដារប្រើប្រាស់សារជាតុគីមីរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងអាជ្ញាប័ណ្ណរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សរុប ៧.១៥៩.០៩១ គ.ក្រ (សូមមើលតារាងឧបសម្ព័ន្ធបន្ថែម)

• វត្ថុជាតុដើមនិងឱសថ ដែលមានផ្ទុកសារជាតុគីមីក្នុងតារាង**ទី៤** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលផ្តល់អាជ្ញាប័ណ្ណដោយក្រសួងសុខាភិបាល មាន ៣០០ ក្រាម

• ការនាំចូលសារជាតុញៀនដែលមានក្នុងតារាងឧបសម្ព័ន្ធ ទី២, ទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន របស់ក្រសួងសុខាភិបាល ក្នុងទម្រង់ជាវត្ថុជាតុដើម និងក្នុងទម្រង់ជាសារជាតុញៀនផ្ទុកក្នុងឱសថ មាន ២៣៦ គ.ក្រ ៣៤៧ ក្រាម ២០៥ មីក្រូក្រាម ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

បានចូលរួមនិងសហការសម្របសម្រួល អនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយប្រទេសថៃ ឡាវ និង វៀតណាម ។ តាមរយៈនេះ យើងបានទៅចូលរួមក្នុងកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សានានា ទាំងក្នុង និងក្រៅប្រទេស សរុប **២០** លើក មន្ត្រីចូលរួម **២៥៦** នាក់ (មន្ត្រី អ.ជ.ប.គ.ញ. **៨៣** នាក់) ក្នុងនោះ ៖

- នៅក្នុងប្រទេស ៩ លើក មន្ត្រីចូលរួម ១៦៣ នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ៦៤ នាក់)
- នៅក្រៅប្រទេស ៦ លើក មន្ត្រីចូលរួម ៩៣ នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ១៩ នាក់)

កម្មវិធីទាំងនោះរួមមាន ៖

• កិច្ចប្រជុំជាមួយឯកអគ្គរដ្ឋទូតវៀតណាមប្រចាំនៅកម្ពុជា ពាក់ព័ន្ធនឹងការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិបូទី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

• កិច្ចប្រជុំជាមួយគណៈប្រតិភូនៃមជ្ឈមណ្ឌលសម្របសម្រួលកិច្ចការស៊ើបអង្កេត នៃក្រសួងការពារជាតិថៃ ពាក់ព័ន្ធគម្រោងមេគង្គក្រោម

• កិច្ចសហប្រតិបត្តិការឆ្លងដែនសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀនជួរមុខ កម្ពុជា-ថៃ
• កិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន លើកទី១១
• វគ្គបណ្តុះបណ្តាលស្តីពីការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
• វគ្គបណ្តុះបណ្តាលស្តីពីយុទ្ធសាស្ត្រកំចាត់ការរត់ពន្ធគ្រឿងញៀនឆ្លងកាត់ព្រំដែន ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

បានចូលរួម និងសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ អន្តរជាតិ ដូចជា សន្និសីទ វេទិកាសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ កិច្ចប្រជុំប្រចាំឆ្នាំ ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ សិក្ខាសាលា និងទស្សនកិច្ចសិក្សា ទាំងក្នុង និងក្រៅប្រទេស សរុប **៦០** លើក មន្ត្រីចូលរួម **៤១១** នាក់ (មន្ត្រី អ.ជ.ប.គ.ញ. **១០៩** នាក់) ក្នុងនោះ ៖

- នៅក្នុងប្រទេស ៨ លើក មន្ត្រីចូលរួម ២១០ នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ៥៤ នាក់)

នៅក្រៅប្រទេស ៣១ លើក មាន ១០ ប្រទេសគឺ វៀតណាម ថៃ ចិន ជប៉ុន កូរ៉េ សឹង្ហបុរី ហូឡង់ អាហ្វ្រិក ហ្វីលីពីន ម៉ាឡេស៊ី មន្ត្រីចូលរួម ២០១ នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ៥៥ នាក់) ។ កម្មវិធីទាំងនោះរួមមាន ៖

- កិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការផែនការអាស៊ាន ដើម្បីប្រឆាំងការផលិតនិងការចរាចរគ្រឿងញៀនខុសច្បាប់ក្នុងតំបន់ត្រីកោណមាស
- កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីផែនការប្រយុទ្ធប្រឆាំងការផលិត និងការជួញដូរគ្រឿងញៀនខុសច្បាប់ ក្នុងតំបន់ត្រីកោណមាស
- វគ្គបណ្តុះបណ្តាលសមត្ថភាពមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែនBLO ក្នុងមហាអនុតំបន់ទន្លេមេគង្គ
- កិច្ចសហប្រតិបត្តិការតំបន់ត្រីកោណមាស ក្រោមផែនការប្រតិបត្តិការ៣ឆ្នាំ (២០១៦-២០១៨) សម្រាប់គម្រោងសុវត្ថិភាពទន្លេមេគង្គ
- កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ និងថ្នាក់រដ្ឋមន្ត្រីប្រទេសហត្ថលេខីលើអនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣
- កិច្ចប្រជុំទ្វេភាគីកម្ពុជា-ចិនលើកទី៧ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន
- កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីបញ្ហាគ្រឿងញៀន (ASOD) លើកទី៣៨
- វគ្គបណ្តុះបណ្តាលអាស៊ាន ស្តីពីការតាមដាននិង វាយតម្លៃកម្មវិធីអប់រំបង្ការគ្រឿងញៀន
- សិក្ខាសាលាកំរិតបច្ចេកទេសនៃមជ្ឈមណ្ឌលព័ត៌មាន និងសម្របសម្រួលប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មគ្រឿងញៀនអាស៊ីប៉ាស៊ីហ្វិច (APICC)។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ របស់រាជរដ្ឋាភិបាល អ.ជ.ប.គ.ញ. បានពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈ ៖

៧.១. ការរៀបចំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីត្រួតពិនិត្យលទ្ធផលការងាររបស់ខ្លួនរយៈពេល ៩ខែ ឆ្នាំ២០១៧ ។

៧.២. ការរៀបចំកិច្ចប្រជុំគណៈកម្មការទាំង៦ និងអនុគណៈកម្មការ៣ របស់ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ព្រមទាំងរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តផែនការឱ្យមានប្រសិទ្ធភាព ។

៧.៣. ការដឹកនាំអនុវត្តផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២០១៦-២០១៨) ។

៧.៤. ការដឹកនាំអនុវត្តតាមទិសដៅការងារដែលបានដាក់ចេញកាលពីឆ្នាំ២០១៦ ។

៧.៥. ការកែសម្រួលមាត្រា៩៧ និងមាត្រាមួយចំនួននៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ។

៧.៦. ការបញ្ចប់សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាពក្រុមលេខា នៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ។

## IV. ការសន្និដ្ឋាន និងវាយតម្លៃ

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖

**ចំណុចខ្លាំង ៖**

បើទោះបីជាចំនួនអ្នកទទួលការផ្សព្វផ្សាយអប់រំមានការថយចុះជាងឆ្នាំ២០១៦ក៏ពិតមែន ប៉ុន្តែការផ្សព្វផ្សាយអប់រំនៅក្នុងឆ្នាំ២០១៧ មានលក្ខណៈច្បាស់លាស់ ដែលក្នុងនោះ៖

- បានរៀបចំឱ្យមានជាផែនការសកម្មភាពជាក់លាក់ និងមានលក្ខណៈពហុវិស័យ ដោយបានកំណត់នូវក្រុមគោលដៅ និងបែងចែកការទទួលខុសត្រូវច្បាស់លាស់ដល់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីខេត្ត ដើម្បីធានាថា គ្រប់ក្រុមគោលដៅ ពិសេសក្រុមគោលដៅប្រឈមនានា បានទទួលសារ ឬការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន
- ផ្អែកទៅលើផែនការសកម្មភាពដែលបានកំណត់ ក្រសួង ស្ថាប័ន អង្គភាព ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីខេត្តពីថ្នាក់ខេត្តរហូតដល់ថ្នាក់មូលដ្ឋានឃុំសង្កាត់ ភាគច្រើនបានយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់
- ជនបង្គោលរបស់ក្រសួង ស្ថាប័ន អង្គភាពមួយចំនួន បានធ្វើសកម្មភាពផ្សព្វផ្សាយអប់រំជាបណ្តើរៗ បើទោះបីជាសមត្ថភាពនៅមានកម្រិត និងត្រូវការគាំទ្រពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនក៏ដោយ
- ទទួលបានការចូលរួម និងគាំទ្រកាន់តែច្រើនឡើងៗ ពីគ្រប់សមាសភាពសង្គម ពិសេសការចូលរួម និងគាំទ្រពីស្ថាប័នជាតិសំខាន់ៗ ដូចជាព្រឹទ្ធសភា រដ្ឋសភា កាកបាទក្រហមកម្ពុជា ក៏ដូចជាការចូលរួម និងគាំទ្រពីវិស័យសាសនា វិស័យឯកជន មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ លោកគ្រូអ្នកគ្រូ និស្សិត សិស្សានុសិស្ស ប្រព័ន្ធផ្សព្វផ្សាយវិទ្យុទូរទស្សន៍ ប្រព័ន្ធទំនាក់ទំនងសង្គម រួមផ្សំជាមួយនឹងការចូលរួម និងគាំទ្រកាន់តែសកម្ម និងផុលផុសរបស់ប្រជាពលរដ្ឋ ធ្វើឱ្យការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនកាន់តែមានភាពងាយស្រួល និងកាន់តែស៊ីជម្រៅ ។

**ចំណុចខ្សោយ ៖**

- ក្រសួង ស្ថាប័ន អង្គភាព ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តមួយចំនួនតូច នៅតែមិនទាន់បានយកចិត្តទុកដាក់ និងទទួលខុសត្រូវអនុវត្តឱ្យបានសកម្មនូវរាល់ភារកិច្ចដែលបានកំណត់ និងបែងចែកក្នុងផែនការសកម្មភាព ឬបានចូលរួមអនុវត្តផែនការយុទ្ធនាការបានសកម្មហើយ ប៉ុន្តែមិនបានផ្ញើរបាយការណ៍មកលេខាធិការដ្ឋាននៃផែនការយុទ្ធនាការឱ្យបានទៀងទាត់
- ការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន តាមរយៈការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម មានការថយចុះ
- ក្រុមគោលដៅប្រឈមសំខាន់ៗ រួមមានដូចជា ក្រុមពលករចល័ត ឬពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រកាត់ដេរ អ្នកបើកបររថយន្តដឹកជញ្ជូន អ្នកបម្រើសេវាកម្សាន្តសប្បាយ សិស្សគេចសាលា នៅតែជាក្រុមគោលដៅដែលពិបាកផ្តល់ការផ្សព្វផ្សាយអប់រំ
- ការបិទផ្សាយសារអប់រំពីបញ្ហាគ្រឿងញៀននៅលើផលិតផល នៅតែមិនទាន់មានលក្ខណៈទូលំទូលាយ
- ជនបង្គោលរបស់ក្រសួង ស្ថាប័ន អង្គភាព និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីខេត្ត ដែលបានទទួលការបណ្តុះបណ្តាលរួច ភាគច្រើននៅមិនបានធ្វើសកម្មភាពឱ្យស្របទៅនឹងស្ថានភាព ជាក់ស្តែងនៃបញ្ហាគ្រឿងញៀន

- រដ្ឋបាលមូលដ្ឋានឃុំសង្កាត់ ក៏ដូចជាប៉ុស្តិ៍នគរបាលរដ្ឋបាលមួយចំនួន នៅតែមិនទាន់ទទួលខុសត្រូវដើរតួជាកម្លាំងជួរមុខក្នុងការបង្ការ ទប់ស្កាត់ និងដោះស្រាយរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន នៅក្នុងមូលដ្ឋានរបស់ខ្លួន ហើយភាគច្រើនពឹងផ្អែកទៅលើកិច្ចអន្តរាគមន៍ពីសមត្ថកិច្ច ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖**

**ចំណុចខ្លាំង ៖**

ចំនួនអ្នកប្រើប្រាស់គ្រឿងញៀនមានការថយចុះ បើធៀបឆ្នាំ២០១៦ អាស្រ័យដោយ ៖

- គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បានពង្រឹងយន្តការ និងលើកកម្ពស់សមត្ថភាពការងាររបស់ខ្លួនពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន
- កិច្ចសហការកាន់តែប្រសើររវាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ពិសេសកិច្ចសហការល្អរវាងអង្គភាពអនុវត្តច្បាប់ ព្រះរាជអាជ្ញា តុលាការ និង អង្គភាពផ្តល់សេវាសុខភាព
- ការកើនឡើងនូវការយល់ដឹង និងភ្ញាក់រលឹករបស់ប្រជាពលរដ្ឋ ក្នុងការបញ្ជូនកូនចៅដែលប្រើប្រាស់ ឬញៀនគ្រឿងញៀនឱ្យទៅទទួលយកសេវាព្យាបាល និងស្តារនីតិសម្បទា ។

**ចំណុចខ្វះខាត ៖**

- នៅមានអ្នកប្រើ និងអ្នកញៀនគ្រឿងញៀនប្រមាណ ១២,៧៤% មិនទាន់បានទៅទទួលការព្យាបាល និងស្តារនីតិសម្បទា ដែលបញ្ហានេះអាចបណ្តាលមកពីការខ្លាចអារចំពោះការអនុវត្តច្បាប់ ឬការមិនយល់ដឹងច្បាស់លាស់ពីការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទា
- មណ្ឌលបណ្តោះអាសន្នភាគច្រើនប្រឈមនឹងភាពណែនចង្អៀត
- យន្តការ និងសេវាគាំទ្រក្នុងដំណាក់កាលនៃការធ្វើសមាហរណកម្ម ដូចជា ការបណ្តុះបណ្តាលបំណិនជីវិត ការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅមិនទាន់មានភាពសកម្ម
- ការតាមដាន និងវាយតម្លៃលើការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនទាំងនៅតាមមណ្ឌលបណ្តោះអាសន្ន និងនៅតាមសហគមន៍ នៅមិនទាន់បានទៀងទាត់ និងមានភាពច្បាស់លាស់
- ការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀនដែលជាពិរុទ្ធជន-ទណ្ឌិតនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនៅតែមិនទាន់ដំណើរការបានល្អ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖**

**ចំណុចខ្លាំង ៖**

មន្ត្រីអនុវត្តន៍ច្បាប់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទទួលបាននូវការបណ្តុះបណ្តាលជាបន្តបន្ទាប់ គួបផ្សំនឹងការអនុវត្តជាក់ស្តែង រួមជាមួយការប្រើប្រាស់កម្លាំងសរុប ធ្វើឱ្យការស្រាវជ្រាវ ស៊ើបអង្កេតបទល្មើសកាន់តែមានប្រសិទ្ធភាព ។ ជាមួយនេះ តាមរយៈកិច្ចសហការផ្តល់ព័ត៌មានរហ័សឱ្យគ្នាទៅវិញទៅមកជាមួយប្រទេសជិតខាងបានល្អ ធ្វើឱ្យការទប់ស្កាត់និងបង្ក្រាបបទល្មើសបានច្រើនករណីធំៗ ។ តាមរយៈការអនុវត្តផែនការយុទ្ធនាការនេះ បានធ្វើឱ្យបទល្មើសគ្រឿងញៀន ក៏ដូចជាបទល្មើសព្រហ្មទណ្ឌមានការការថយចុះ ។

**បញ្ហាប្រឈម ៖**

- បណ្តាខេត្តនៅភាគឦសានប្រទេស នៅតែជាខេត្តដែលបន្តមានសកម្មភាពលួចចរាចរនាំចូលគ្រឿងញៀនដោយខុសច្បាប់ ទោះបីយើងបង្ក្រាបបានចំករណីធំៗ និងកាត់ផ្តាច់ខ្សែរយៈទាក់ទងជាច្រើនហើយក៏ដោយ

- ឧក្រិដ្ឋជនអន្តរជាតិ នៅតែព្យាយាមប៉ុនប៉ងប្រើប្រាស់កម្ពុជា ធ្វើជាប្រទេសផលិតកែច្នៃ និងឆ្លងកាត់គ្រឿងញៀនខុសច្បាប់ តាមគ្រប់រូបភាព ទាំងផ្លូវគោក ទឹក និង អាកាស

- ឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិបានបោះទុនយ៉ាងច្រើនទៅឱ្យតំបន់តំបន់ត្រីកោណមាស ដើម្បីផលិតគ្រឿងញៀនសម្រាប់ធ្វើការចែកចាយនៅទូទាំងតំបន់

- ស្ថានភាពនយោបាយក្នុងប្រទេសមីយ៉ាន់ម៉ាបានជំរុញឱ្យអតីតក្រុមជនជាតិភាគតិច និងក្រុមថ្មីផ្សេងទៀតដែលទើបកើតឡើងផលិតគ្រឿងញៀន ដើម្បីលក់យកប្រាក់សម្រាប់មូលនិធិនិងសេចក្តីត្រូវការរបស់ក្រុមពួកគេ។

**ចំណុចខ្សោយ ៖**

- ការបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធនឹងច្បាប់នានា, ជំនាញប្រតិបត្តិការបង្ក្រាបបទល្មើស, នីតិវិធីក្នុងការកសាងសំណុំរឿង នៅថ្នាក់ជាតិយើងធ្វើបានច្រើន ប៉ុន្តែនៅថ្នាក់ខេត្តយើងបណ្តុះបណ្តាលបានតិច ដែលមិនអាចជួយដោះបន្ទុកប្រតិបត្តិការបង្ក្រាបបទល្មើសរបស់ថ្នាក់ជាតិបានទាន់ពេលវេលា

- ម្ចាស់ទីតាំងផ្ទះសំណាក់ ផ្ទះជួល អាជីវកម្ម សេវាកម្មកម្សាន្តមួយចំនួន នៅក្នុងភូមិសាស្ត្រងាយកើតមានបទល្មើស មិនរាយការណ៍ មិនសហការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនដល់សមត្ថកិច្ច ឬផ្តល់ព័ត៌មានមកសមត្ថកិច្ចយឺតយាវ

- ម្ចាស់ទីតាំងផ្ទះសំណាក់ ផ្ទះជួល អាជីវកម្ម សេវាកម្មកម្សាន្តមួយចំនួន ឆ្លៀតឱកាសនេះ ឃុបឃិតទាញយកផលប្រយោជន៍ពីជនល្មើស ពីអ្នកប្រើប្រាស់ តាមរូបភាពផ្សេងៗគ្នា

- បញ្ហាថវិកា មធ្យោបាយ សម្ភារ សម្រាប់បម្រើឱ្យកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន នៅតែជាបញ្ហាចោទចំពោះមុខដែលត្រូវដោះស្រាយ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

**ចំណុចខ្លាំង ៖**

ដោយមានកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ យើងគ្រប់គ្រងបានជាប់ជាប្រចាំនូវទិន្នន័យសារធាតុគីមីផ្សំដែលមានការអនុញ្ញាតឱ្យនាំចូល ។ តាមរយៈការបណ្តុះបណ្តាលសមត្ថភាព មន្ត្រីអនុវត្តន៍ច្បាប់យើងកាន់តែមានបទពិសោធន៍ក្នុងការបង្ការ ទប់ស្កាត់បានការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ យកទៅសំយោគផលិតជាគ្រឿងញៀនខុសច្បាប់ ។

**ចំណុចខ្សោយ ៖**

- យន្តការការងាររបស់ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ដែលបានផ្លាស់ប្តូរសមាសភាពរួចហើយ ក៏នៅមិនទាន់បានបំពេញការងាររបស់ខ្លួននៅឡើយ អាស្រ័យដោយយើងនៅមិនទាន់មានក្រុមលេខា នៃក្រុមការងារនេះ

- ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំដល់សមត្ថកិច្ចពាក់ព័ន្ធ និងបុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី នៅមិនទាន់ធ្វើបានទូលំទូលាយនៅឡើយ

- នៅមិនទាន់មានការត្រួតពិនិត្យបានច្បាស់លាស់ពីការចរាចរ ការប្រើប្រាស់ និងសន្និធិសារធាតុគីមីផ្សំដែលប្រើប្រាស់ដោយសិប្បកម្មក្នុងស្រុកនានា ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

**ចំណុចខ្លាំង ៖**

កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងយន្តការនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ជាមួយបណ្តាប្រទេស

ជាប់ព្រំដែន កម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម តាមរយៈ ការជួយបណ្តុះបណ្តាលជំនាញដល់មន្ត្រីអនុវត្តន៍ច្បាប់នៅទូទាំងប្រទេស ការផ្តល់មធ្យោបាយ និងសម្ភារ បរិក្ខារចាំបាច់មួយចំនួនជួយសម្រួលដល់សេចក្តីត្រូវការចំពោះមុខ និងការផ្តល់ថវិកាដើម្បីទ្រទ្រង់សកម្មភាពអាទិភាពត្រួតពិនិត្យគ្រឿងញៀន។ យន្តការនៃការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកទាក់ទងនឹងបទល្មើសគ្រឿងញៀន ដើម្បីឈានទៅដល់ការទប់ស្កាត់ និងបង្ក្រាបទាន់ពេលនូវករណីជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែន កាន់តែត្រូវបានលើកកំពស់និងសកម្មជាងមុន។ ជាងនេះទៅទៀត កម្ពុជា ឡាវ ថៃ បានឯកភាពគ្នារៀបចំកសាង "ភូមិសគ្មានគ្រឿងញៀន" នៅតំបន់ព្រំដែន កម្ពុជា-ឡាវ (២ភូមិ) កម្ពុជា-ថៃ (៣ភូមិ) និងការិយាល័យ BLO ចំនួន៥។

**ចំណុចខ្សោយ ៖**

ទោះបីជាយើងបានសហការជាមួយប្រទេសជិតខាងទទួលបានលទ្ធផលជាច្រើនក៏ពិតមែន តែក្រុមឧក្រិដ្ឋជនគ្រឿងញៀននៅតែបន្តជួញដូរគ្រឿងញៀនឆ្លងកាត់កម្ពុជា ទៅកាន់ប្រទេសទីបី។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖**

**ចំណុចខ្លាំង ៖**

កម្ពុជាបានពង្រឹង និងពង្រីកសមត្ថភាពត្រួតពិនិត្យគ្រឿងញៀនរបស់ខ្លួនជាប់ជាប្រចាំ ដោយបានចូលរួមយ៉ាងសកម្មជាមួយយន្តការត្រួតពិនិត្យគ្រឿងញៀន ទាំងក្នុងកម្រិតអនុតំបន់ តំបន់ និងអន្តរជាតិ។

**ចំណុចខ្សោយ ៖**

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការជួយគាំទ្រជាថវិកា មធ្យោបាយ និងសម្ភារ ពីបណ្តាប្រទេសផ្តល់ជំនួយក៏ដូចជាដៃគូអភិវឌ្ឍន៍នានា លើសកម្មភាពត្រួតពិនិត្យគ្រឿងញៀន បានកាត់បន្ថយមកនៅក្នុងកម្រិតតិចតួចបំផុត ដែលទាំងអស់នេះបាន ជះឥទ្ធិពលមិនល្អដល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀនទាំងនៅកម្ពុជា និងក្នុងតំបន់។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖**

**ចំណុចខ្លាំង ៖**

ជារួម នៅថ្នាក់ជាតិយើងមានយន្តការត្រួតពិនិត្យគ្រឿងញៀនពហុវិស័យ សម្រាប់ចង្អុលដឹកនាំ និងណែនាំបញ្ជាទៅថ្នាក់ខេត្ត ។ នៅរាជធានី ខេត្ត យើងមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ជាខ្សែបណ្តោយសម្រាប់អនុវត្តយុទ្ធសាស្រ្តត្រួតពិនិត្យគ្រឿងញៀនពហុវិស័យ ។

**ចំណុចខ្សោយ ៖**

- យន្តការត្រួតពិនិត្យគ្រឿងញៀនរបស់រាជធានី-ខេត្តមួយចំនួន អនុវត្តមិនទាន់បានជាលក្ខណៈពហុវិស័យ

- បានបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនដល់ថ្នាក់សង្កាត់-ឃុំរួចហើយ តែសកម្មភាពការងារមិនទាន់អនុវត្តបានជាប្រចាំ, មិនទាន់បានរៀបចំយន្តការ និងជំរុញលើកទឹកចិត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនស្របតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

- មាត្រាមួយចំនួនពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលនៃបទល្មើសគ្រឿងញៀន ដែលបានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅមិនទាន់បានកែសម្រួលគ្រប់គ្រាន់នៅឡើយ

- ការអនុវត្តគោលនយោបាយលើកទឹកចិត្តដល់អង្គភាព និងបុគ្គលដែលមានស្នាដៃ ក្នុងការងារផ្សព្វផ្សាយអប់រំការព្យាបាលនិងស្តារនីតិសម្បទា ការងារអនុវត្តច្បាប់ និងការលើកទឹកចិត្តចំពោះអតីតអ្នកញៀនគ្រឿងញៀន ក្រុមគ្រួសារ និងសហគមន៍របស់គេ នៅមិនទាន់បានអនុវត្ត ។

## V. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៨

ផ្អែកលើការសន្និដ្ឋានវាយតម្លៃ និងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវទិសដៅសម្រាប់អនុវត្តនៅក្នុងឆ្នាំ២០១៨ ដូចខាងក្រោម ៖

**១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖**

- បន្តជំរុញការអប់រំផ្សព្វផ្សាយ តាមគ្រប់រូបភាពជាប្រចាំ និងចំគោលដៅប្រឈមពិតប្រាកដ និងក្រុមដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ព្រមទាំងបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមមូលដ្ឋាន
- បន្តរៀបចំធ្វើបច្ចុប្បន្នភាពលើ ខ្លឹមសារអប់រំផ្សព្វផ្សាយដើម្បីឱ្យមានភាពទាក់ទាញពីមហាជនទូទៅ ក៏ដូចជាដល់ក្រុមជនគោលដៅងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ពិតប្រាកដ
- បន្តចលនា លើកទឹកចិត្តដល់អាណាព្យាបាល ក៏ដូចជាវិស័យឯកជន ក្នុងការចូលរួមលើការងារអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀន រួមទាំងបង្កើនការបិទសារអប់រំលើផលិតផលនានា
- បន្តការចងក្រងយន្តការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងការអប់រំសីលធម៌បដិសេធគ្រឿងញៀន នៅតាម គ្រឹះស្ថានសិក្សាគ្រប់កម្រិត និងមជ្ឈមណ្ឌលសហគមន៍
- បន្តជំរុញនិងលើកទឹកចិត្តគ្រូបង្រៀន សិស្ស និស្សិត និងគរុសិស្សចូលរួមបង្ការ ទប់ស្កាត់ និងលុបបំបាត់គ្រឿងញៀននៅក្នុងសង្គម តាមរូបភាពសិល្បៈអប់រំ ដូចជាគូរគំនូរ តែងចម្រៀង តែងកំណាព្យ លេងកីឡា និងសិល្បៈ ។ល។ និង ។ល។
- បន្តលើកទឹកចិត្តដល់អតីតអ្នកញៀនគ្រឿងញៀន និងក្រុមគ្រួសារដែលបានចាកចេញពីគ្រឿងញៀន ដើម្បីឱ្យពួកគេចូលរួមក្នុងការអប់រំមហាជនឱ្យចេះបដិសេធគ្រឿងញៀន
- បន្តចលនាឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អង្គការសាសនា វិស័យឯកជន សំដៅកាត់បន្ថយតម្រូវការគ្រឿងញៀន តាមគ្រប់រូបភាព គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖**

- បន្តការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឬទី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
- បន្តចលនាឱ្យមានការចូលរួមពីគ្រប់បុគ្គល និងអង្គភាព ចូលរួមបំផុសនិងលើកទឹកចិត្តឱ្យមានការទៅទទួលយកសេវាព្យាបាលដោយស្ម័គ្រចិត្ត
- បន្តពង្រឹងគុណភាព សមត្ថភាព ទាំងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ក៏ដូចជាកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ដោយមានយន្តការដាក់លាក់ទៅលើខ្លឹមសារបីគឺ ៖ ការព្យាបាល, ការបណ្តុះបណ្តាលវិជ្ជាជីវៈ, ការធ្វើសមាហរណកម្ម ព្រមទាំងជំរុញការអនុវត្តនូវវិធានការគាំទ្រ លើកទឹកចិត្ត រដ្ឋបាល និងវិធានការច្បាប់
- បន្តវិធានការថែទាំសុខភាពអ្នកដែលបានចាកចេញពីគ្រឿងញៀន ព្រមទាំងបន្តពង្រឹងកិច្ចសហការរវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការជាដៃគូ ដើម្បីដោះស្រាយបញ្ហាគ្រឿងញៀន និងមេរោគអេដស៍ ជំងឺអេដស៍
- បន្តពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីអនុវត្តតាមតួនាទី ភារកិច្ច បន្សាប ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មចំពោះអ្នកចាកចេញពីគ្រឿងញៀនទៅកាន់គ្រួសារ និងសហគមន៍វិញ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖**

- បន្តចាត់វិធានការគ្រប់បែបយ៉ាងតាមផ្លូវច្បាប់ និងរដ្ឋបាល ដើម្បីប្រឆាំងការផលិត ការជាំជុះ ការចម្រាញ់ ការចរាចរជួញដូរ ការស្តុកទុក ការប្រើប្រាស់គ្រឿងញៀន រួមទាំងទីតាំងសម្រួលឱ្យប្រើប្រាស់ តាមគ្រប់រូបភាព

- បន្តលើកកម្ពស់គុណភាពនៃការអនុវត្តច្បាប់ ដើម្បីបំផ្លាញអង្គការចាត់តាំង និងឧបាយកលថ្មីៗរបស់ឧក្រិដ្ឋជនគ្រឿងញៀន ដោយសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង និងអន្តរជាតិ ទប់ស្កាត់ការហូរចូលឱ្យបានជាអតិបរមានូវគ្រឿងញៀនគ្រប់ប្រភេទតាមតំបន់ព្រំដែន ជាពិសេសព្រំដែនកម្ពុជា-ឡាវ

- បន្តពង្រឹងការយល់ដឹង សមត្ថភាព ឆន្ទៈ គុណធម៌ វិជ្ជាជីវៈ និងការទទួលខុសត្រូវនៃស្ថាប័នអនុវត្តន៍ច្បាប់ សំដៅបង្កើនគុណភាពនិងកាត់បន្ថយភាពអសកម្មនានា ដែលជាការមិនស្មោះត្រង់ចំពោះវិជ្ជាជីវៈ និងការទទួលខុសត្រូវ

- បន្តពង្រឹងយន្តការចូលរួមនិងលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ក្នុងការកសាងសំណុំរឿង ដើម្បីដាក់ទោសជនល្មើសឱ្យបានខ្លាំងក្លាថែមទៀត ស្របតាមខ្លឹមសារនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

- បន្តជំរុញការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ពាក់ព័ន្ធនានា ដល់តំបន់គោលដៅងាយកើតមានបញ្ហាគ្រឿងញៀន ដូចជា ផ្ទះសំណាក់ ផ្ទះជួល សណ្ឋាគារ មណ្ឌលកម្សាន្តនានា ជាដើម

- បន្តកិច្ចសហការជាមួយធនាគារអភិវឌ្ឍន៍ពិភពលោក ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រពង្រឹងប្រសិទ្ធភាពប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

- បញ្ចប់ការកែសម្រួលសេចក្តីសម្រេចស្តីពីការបង្កើតក្រុមលេខា នៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ

- បន្តកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំដែលនាំចូលស្របច្បាប់ និងមិនស្របច្បាប់ ព្រមទាំងវត្ថុធាតុដើម ឬសារធាតុផ្សំមួយចំនួនទៀត

- បន្តកិច្ចសហការបង្ការ ទប់ស្កាត់ ការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ យកទៅសំយោគផលិតជាគ្រឿងញៀនខុសច្បាប់

- បន្តការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ ដល់មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធនានា និងបុគ្គលិករោងចក្រ សហគ្រាស ក្រុមហ៊ុន និងឧស្សាហកម្មដែលប្រើប្រាស់សារធាតុគីមី ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

- បន្តការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង តាមគ្រប់រូបភាព ដោយផ្តោតសំខាន់លើការទប់ស្កាត់ការចរាចរគ្រឿងញៀន តាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស

- បន្តពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រដែន (BLO) កម្ពុជា-ឡាវ-ថៃ និងវៀតណាម

- បន្តការអនុវត្តគម្រោងមេគង្គក្រោម (Low Mekong) សម្រាប់ប្រទេសកម្ពុជា ថៃ និង ឡាវ ពីឆ្នាំ២០១៩-២០២០

- បន្តសហការជាមួយភាគីវៀតណាម ក្នុងការពន្លឿនការផ្តល់ថវិកាក្នុងការសាងសង់មជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀនដោយស្ម័គចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តព្រះសីហនុ រួមនិងការលើកកម្ពស់កិច្ចសហប្រតិបត្តិការថ្មីៗបន្ថែមទៀតក្នុងក្របខ័ណ្ឌនៃការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បន្តអនុវត្តតាមអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគីកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ដែលបានឯកភាពគ្នាកន្លងមក ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖**

- បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីពង្រឹងនិងពង្រីកកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីគ្រឿងញៀន

- បន្តបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន ពិសេសពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូជាតិ-អន្តរជាតិ ដើម្បីស្វែងរកមូលនិធិគាំទ្រ លើការងារព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍

- បន្តកៀរគរបណ្តាប្រទេសផ្តល់ជំនួយនិងដៃគូអភិវឌ្ឍន៍នានា ពិសេសអង្គការ UNODC ដើម្បីគាំទ្រសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា តាមរយៈការអនុវត្តផែនការសកម្មភាពរបស់បណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ

- បន្តការចូលរួមគ្រប់វេទិកាទាំងក្នុងតំបន់និងអន្តរជាតិ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ការចរាចរជួញដូរគ្រឿងញៀន

- បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-កូរ៉េ សំដៅពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់គ្រឿងញៀន និងគាំទ្រដល់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

- បន្តចូលរួមអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project) ពីឆ្នាំ២០១៩-២០២១

- បន្តចូលរួមអនុវត្តគម្រោងអនុតំបន់ តំបន់មួយចំនួន រួមមាន៖ គម្រោង PATROL, Container Control Program, AirCago និង eLearning របស់អង្គការ UNODC Mekong Project របស់សាធារណរដ្ឋកូរ៉េ

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖**

- បន្តត្រៀមចូលរួមអនុវត្តផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់រាជរដ្ឋាភិបាល

- បន្តដឹកនាំការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បន្តពង្រឹងស្ថាប័នសេនាធិការ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាជ្ញាធរពាក់ព័ន្ធទាំងអស់ ដើម្បីពង្រីកលទ្ធភាពអនុវត្តវិធានការយុទ្ធសាស្ត្រពហុវិស័យរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យមានប្រសិទ្ធភាព

- បន្តរៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីនគរបាលយុត្តិធម៌ថ្នាក់ក្រោមជាតិនៅតាមបណ្តាខេត្តគោលដៅមួយចំនួន

- បន្តការអនុវត្តអនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បន្តរៀបចំខ្លឹមសារសេចក្តីព្រាងទាក់ទងនឹងមាត្រាមួយចំនួន ដែលបានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន

- បន្តអនុវត្តគោលនយោបាយលើកទឹកចិត្តដល់អង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមមាន ស្នាដៃលើការងារផ្សព្វផ្សាយអប់រំ ស្នាដៃការព្យាបាលនិងស្តារនីតិសម្បទា ស្នាដៃក្នុងការអនុវត្តច្បាប់ លើកទឹកចិត្តចំពោះអតីតអ្នកញៀនគ្រឿងញៀន ក្រុមគ្រួសារ និងសហគមន៍របស់គេ ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលតែងតែណែនាំ និងតម្រង់ទិសលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជួយឧបត្ថម្ភ គាំពារលើការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១ និង លើកទី២ ប្រកបដោយការទទួលខុសត្រូវ និងទទួលបាននូវការគាំទ្រ និងវាយតម្លៃខ្ពស់ពីសាធារណមតិជាតិ និងអន្តរជាតិ ក៏ដូចជាប្រជាពលរដ្ឋទូទៅ ។

សូមថ្លែងអំណរគុណផងដែរ ដល់គ្រប់ប្រធានក្រសួង ស្ថាប័ន ព្រមទាំងមន្ត្រីរាជការក្រោមឱវាទ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ផ្នែកសាសនា បុគ្គលពាក់ព័ន្ធ ក៏ដូចជាសមាគមសង្គ្រោះនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការគាំទ្រ ការកសាងមជ្ឈមណ្ឌលជាតិផ្តល់សេវា ព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងនៅកន្លែងផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន សប្បុរសជន សិល្បករ ក៏ដូចជាប្រជាពលរដ្ឋ ដែលបានចូលរួមចំណែកជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការធ្វើឱ្យបានសម្រេចលទ្ធផលជាផ្លែផ្កាដូចមានក្នុងរបាយការណ៍ខាងលើ ។

សូមអំពាវនាវដល់គ្រប់សមាសភាពពាក់ព័ន្ធទាំងអស់ បន្តការគាំទ្រដល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីអនុវត្តកម្មវិធីការងារឱ្យកាន់តែទទួលបានលទ្ធផលជោគជ័យថ្មីៗបន្ថែមទៀត តាមទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញសម្រាប់អនុវត្តនៅក្នុងឆ្នាំ២០១៨ ខាងមុខនេះ ។

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**នាយឧត្តមសេនីយ៍. កែ_គឹមយ៉ាន**

**ចម្លងជូន** :

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

" ដើម្បីជូនជ្រាប "

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត

-នាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីមុខការ "

-ឯកសារ-កាលប្បវត្តិ